**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្ត ឧត្តរមានជ័យ**

លេខ: ២៣៦ ស.ខ.ឧ.ម.ជ

*ឧត្តរមានជ័យ.ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៤*

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៥

**រដ្ឋបាលខេត្ត ឧត្តរមានជ័យ** នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៥ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីអ្នកទទួលការមានសិទ្ធិ ដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់នៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកទទួលការត្រូវបានបែងចែកជា *០៣* ប្រភេទ ៖

- *ប្រភេទទី ១*: អ្នកទទួលការសំណង់ទូទៅ ( ការងារសំណង់អគារ និងការងារបេតុង...។ល។)
- *ប្រភេទទី ២*: អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រាលគ្រួសក្រហម.....។ល។)
- *ប្រភេទទី ៣*: អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញពិសេស សម្រាប់ ការងារពិសេសដូចជា អណ្តូងស្នប់...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស សម្ភារៈ និងបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចចំនួន ០២ ក្នុងអំឡុងពេល ០៥ ឆ្នាំចុងក្រោយ ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ និងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេស ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចបានបរិយាយក្នុងពាក្យស្នើសុំចុះបញ្ជី ព្រមទាំងពិនិត្យគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច ។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធ នឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកហូតសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ និងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ ។

អាស្រ័យហេតុនេះ បើអ្នកទទួលការណាមានបំណងចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យនៅទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី *១០* ខែ *តុលា* ឆ្នាំ *២០១៤* វេលាម៉ោង *០៥.០០* ល្ងាច ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យជាថ្មីឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះនៅទីចាត់ការផែនការ និងវិនិយោគសាលាខេត្តដោយឥតគិតថ្លៃ រៀងរាល់ម៉ោងធ្វើការ ឬទាញយកពីគេហទំព័រ គ.ជ.អ.ប ។

**អភិបាលខេត្ត**

**ស. ថាវី**